គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ថុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យិម ប៉ូ
Mr. YIM Po អគ្គហិរញ្ញិក
និងនាយក CCPCR

លោក សុខ សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទីវ សារ៉ាយេត
Ms. TIV Sarayet
សហនាយិកា WMC

លោក យង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សេន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម្ព
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ០១/០៧ គ.យ.ស.ប/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# របាយការណ៍ស្តីពី
# លទ្ធផលជាសូចនាករច្បាស់លាស់[1] នៃការសង្កេត
# លើការអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា និង
# សកម្មភាពរបស់សភា និងតំណាងរាស្ត្រ អាណត្តិទី៣ គិតមកដល់ដំណាច់ឆ្នាំ ២០០៦

*ភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧*

មកដល់ដំណាច់ឆ្នាំ ២០០៦ នេះ ការសង្កេតរបស់ ខុមហ្វ្រែល រកឃើញថា លទ្ធផលមានសូចនាករច្បាស់លាស់ នៃការសន្យាក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ ច្រើនជាង ៧០% មិនទាន់អនុវត្ត ឬបានអនុវត្តតិចតួច។ ក្នុងចំណោមកម្មវិធីនយោបាយប្រមាណ ៣០% ដែលបានអនុវត្តនោះ នៅក្នុងឆ្នាំ២០០៦ មាន *ការអនុម័តសេចក្តីណែនាំ និងការរៀបចំជ្រើសរើសប្រធាន អនុ និងសមាជិកភូមិ*។ សេចក្តីណែនាំស្តីពីបែបបទនីតិវិធីជ្រើសរើសមេភូមិ បាននាំមកនូវភាពចំរូងចំរាស់ដោយមិនមានការបោះឆ្នោតជ្រើសរើសផ្ទាល់ពីប្រជាពលរដ្ឋ។ការអនុវត្តសេចក្តីណែនាំនេះនាំមកនូវលទ្ធផលលំអៀងទៅរកគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា)។ ជាក់ស្តែងក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សប្រជាជនកម្ពុជា បានគ្របដណ្តប់ក្នុងការសំរេចជ្រើសរើសទទួលបានតំណែងមេភូមិប្រមាណ ៩៨% តំណែងអនុភូមិ ៩៧% តំណែងសមាជិកភូមិប្រមាណ ៩៩% ធៀបនឹងចំនួនសរុបនៃគណបក្សនយោបាយទាំងបីដែលមានអាសនៈក្នុងសភា។ ចំណែកស្ត្រីជាមេភូមិមានចំនួនតិចតួចបំផុតពោលគឺត្រឹមតែ៣,៤% និងអនុភូមិ ១៦,៣% ប៉ុណ្ណោះ។

ចំណុចសន្យាសំខាន់ៗដែលរាជរដ្ឋាភិបាលមិនទាន់បានបំពេញរួមមាន ការអនុម័ត*ច្បាប់ស្តីពីបាតុកម្ម និងកូដកម្ម ច្បាប់ប្រឆាំងអំពើពុករលួយ និងមិនទាន់បង្កើតស្ថាប័នឯករាជ្យ អព្យាក្រឹត្យ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ*។ ការមិនទាន់អនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ជាចំនុចរសើបក្នុងការពិភាក្សាអំពីការខ្វះឆន្ទៈ និងការមិនគោរពតាមកិច្ចសន្យារបស់រាជរដ្ឋាភិបាល។ ព្រោះថាការសន្យាដើម្បីអនុម័តច្បាប់មានចំនួនច្រើនលើកច្រើនសារមកហើយ ហើយលើកក្រោយនេះ ថានឹងអនុម័តឱ្យរួចនៅខែមិថុនា ឆ្នាំ២០០៦។ រាជរដ្ឋាភិបាលបានពន្យល់មិនច្បាស់លាស់ថា រង់ចាំការអនុម័តច្បាប់ក្រមព្រហ្មទ័ណ្ឌរួចសិន ដើម្បីឱ្យមានការស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ប្រឆាំងអំពើពុករលួយ។ ការពន្យល់នេះមិនស្របគ្នានឹងសកម្មភាពប្រមុខរដ្ឋាភិបាល និងសភាដែលបានជំរុញការអនុម័តច្បាប់ឯកពន្ធភាពបានដោយរយៈពេលខ្លី និងប្រញាប់បំផុតក្នុងការពិភាក្សា ដោយបានកំណត់ទោសព្រហ្មទ័ណ្ឌទៅដល់ជនជាប់ពិរុទ្ធពីបទផិតក្បត់ដោយមិនរង់ចាំក្រមព្រហ្មទ័ណ្ឌ។

---

[1] គឺសំដៅទៅលើលទ្ធផលជាក់ស្តែងនានាដែលអាចវាស់បាន ដូចជាការអនុម័តច្បាប់ បង្កើតស្ថាប័ន ឬ ធ្វើសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ដោយមានគោលដៅ ពេលវេលា ឬ មានចំនួនកំណត់ច្បាស់លាស់។

សម្តេចនាយករដ្ឋមន្ត្រីក៏ធ្លាប់មានប្រសាសន៍ថា រាជរដ្ឋាភិបាលចង់ឃើញការប្រឆាំងអំពើពុករលួយគឺនិយាយដល់"**ការទប់ស្កាត់**"។ ប្រសិនបើច្បាប់នេះ នឹងត្រូវបានអនុម័តស្របនឹងមតិអង្គការមិនមែនរដ្ឋាភិបាល និងអ្នកឯកទេសមួយចំនួនដែលចង់បានច្បាប់ប្រឆាំងអំពើពុករលួយស៊ីសង្វាក់ជាមួយស្តង់ដារអង្គការសហប្រជាជាតិ ពិសេសការប្រកាសទ្រព្យសម្បត្តិមន្ត្រីនយោបាយរបស់រាជរដ្ឋាភិបាល សភា នឹងនាំមកនូវការទប់ស្កាត់អំពើពុករលួយមួយចំនួនធំ។

រាជរដ្ឋាភិបាលបានខិតខំជំរុញ ហើយសភាក៏បានខិតខំអនុម័តវិសោធនកម្មច្បាប់ ច្បាប់សន្ធិសញ្ញា អនុសញ្ញា ពិធីសារ និងកិច្ច-ព្រមព្រៀងនានាចំនួន ៨៣ ប៉ុន្តែ**ច្បាប់សំខាន់ៗសំរាប់ជំរុញកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងការគាំទ្រលទ្ធិប្រជាធិបតេយ្យតួនាទីមតិប្រឆាំង(ជំទាស់)និងការអភិវឌ្ឍស្ថាប័ន មិនទាន់ត្រូវបានអនុម័តនៅឡើយ**។ ច្បាប់ទាំងនោះត្រូវបានសន្យាយ៉ាងច្បាស់លាស់ក្នុងកម្មវិធីនយោបាយ រួមមានដូចជា *ច្បាប់លក្ខន្តិកៈចៅក្រម ក្រមព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសារការី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាសាលា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ*។ មានតែក្រមស្តីពីនីតិវិធីរដ្ឋប្បវេណីមួយប៉ុណ្ណោះ ដែលត្រូវបានរដ្ឋសភាអនុម័តនាខែ ឧសភា ឆ្នាំ ២០០៦។ ***នៅមិនទាន់បង្កើតស្ថាប័នជាតិសំខាន់ៗ*** ដែលបានលើកឡើងនៅក្នុងកម្មវិធីនយោបាយ តួយ៉ាងដូចជា *គណៈកម្មាធិការជាតិសិទ្ធិមនុស្ស* និងតុលាការឯកទេសមួយចំនួន រួមមានជាអាទិ៍ *តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល*។ នៅក្នុងសន្និសីទមួយនៅឯខេត្តសៀមរាប កាលពីថ្ងៃទី២៦-២៧ ខែកញ្ញា ឆ្នាំ២០០៦ **សម្តេចនាយករដ្ឋមន្ត្រី បានជំរុញឱ្យមានការរៀបចំច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនៅកម្ពុជា** ដែលបានស្នើឱ្យអង្គការសង្គមស៊ីវិលចូលរួមរៀបចំសេចក្តីព្រាងច្បាប់ឱ្យបានឆាប់។

*រាជរដ្ឋាភិបាលបានអនុវត្តពេញលេញ នូវការតម្លើងបៀវត្សជូនមន្ត្រីរាជការទូទៅពី ១០% ទៅ ១៥% ក្នុងមួយឆ្នាំ*។ ប៉ុន្តែការតម្លើងនេះ ពុំបានជួយសម្រួលដល់ជីវភាពទេដោយសារតែស្ថានភាពតម្លៃទំនិញឡើងថ្លៃ និងការផ្តល់សេវាសាធារណៈនៅពុំទាន់មានប្រសិទ្ធភាព។ ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ គឺមិនមានការវិវឌ្ឍគួរឱ្យចាប់អារម្មណ៍នោះទេ។ ចំណែកឯ**ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅមានការយឺតយ៉ាវជាខ្លាំង**។ សេចក្តីព្រាងច្បាប់អង្គការសំរាប់ខេត្ត និងស្រុក នៅមិនទាន់បានបើកចំហរសំរាប់ការពិគ្រោះផ្តល់មតិយោបល់នៅឡើយ។

*រាជរដ្ឋាភិបាលបានបំពេញនូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់រហូតដល់ជាង ៧%* បានរៀបចំកម្មវិធីកំណែទម្រង់គ្រប់គ្រង**ហិរញ្ញវត្ថុសាធារណៈដូចការសន្យា និងបានអនុម័តតម្លើងថវិកាជាតិឆ្នាំ ២០០៥ ប្រមាណ ៥% ឆ្នាំ ២០០៦ ប្រមាណ ២០% និងឆ្នាំ ២០០៧ ប្រមាណ ២១%**។ ទោះបីយ៉ាងណាក៏ដោយ ក៏នៅមានកង្វះ*ខាតប្រសិទ្ធភាពក្នុងការចាត់ចែងថវិកាជាតិ និងការធានាឱ្យមានសមធម៌ក្នុងការបែងចែកផ្លែផ្កាពីកំណើនសេដ្ឋកិច្ចនេះ*។ ជាលទ្ធផល វិសមភាព(ភាពមិនស្មើគ្នា) រវាងអ្នកមាន និងអ្នកក្រ គឺនៅតែមានគម្លាតខ្លាំង បើប្រៀបធៀបនឹងប្រទេសជិតខាងដោយប្រទេសកម្ពុជាមានគម្លាត ០,៤២ ប្រទេសលាវ ០,៣៥ និងប្រទេសថៃ ០,៤០[២]។

កង្វះភាពជោគជ័យក្នុងការធានាសមភាពបែងចែកផលនៃកំណើនសេដ្ឋកិច្ចនេះ បានធ្វើឱ្យការសន្យារបស់រាជរដ្ឋាភិបាលក្នុងកម្មវិធីនយោបាយស្តីពី**វិស័យសង្គមកិច្ចជាច្រើន ពុំទាន់ត្រូវបានបំពេញ** ជាក់ស្តែងរាជរដ្ឋាភិបាល*នៅតែមិនទាន់អាចធ្វើឱ្យមានសមធម៌ក្នុងការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំសំរាប់កុមារគ្រប់រូប សេវាពិនិត្យរោគដោយឥតគិតថ្លៃសំរាប់ប្រជាពលរដ្ឋក្រីក្រនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា*។ *ការរក្សាស្ថេរភាពតម្លៃទំនិញសំខាន់ៗ* ចាំបាច់សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

[២] ០ មានន័យថាមាន សមភាពសុក្រិត និង ១ មានន័យថាមាន មិនមានសមភាពទាល់តែសោះ (យោងតាមធនាគារពិភពលោក)។

មិនត្រូវបានអនុវត្តដោយជោគជ័យនោះទេ ព្រោះថា **ប្រេងឥន្ធនៈ ទំនិញ និងស្បៀងអាហារ** ស្ថិតនៅតំលៃថ្លៃដដែល ឬបន្តឡើងថ្លៃ។ ប្រេងឥន្ធនៈ មិនត្រូវបានបញ្ចុះថ្លៃឱ្យស្របតាមការចុះតំលៃទីផ្សារអន្តរជាតិ ហើយក៏មិនស្មើតំលៃក្នុងប្រទេសជិតខាងនោះផងដែរទេ។ កំរិតអ្នករស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនៅកម្ពុជា នៅមានកំរិតខ្ពស់រហូតដល់ ៣៥%។ ក្នុងមួយឆ្នាំប្រទេសកម្ពុជាអាចកាត់បន្ថយភាពក្រីក្រជាមធ្យមតែ ១,១% ចំនួននេះមានកំរិតតិចតួចណាស់បើប្រៀបធៀបជាមួយប្រទេសជិតខាង (នេះបើយោងតាមធនាគារពិភពលោក)។ **មានច្បាប់ចំនួនពីរ ពុំទាន់ត្រូវបានអនុម័ត ក្នុងនោះរួមមាន** ***ច្បាប់គ្រប់គ្រងកាស៊ីណូ និងច្បាប់ស្តីពីតំបន់ឧស្សាហកម្ម។***

**ចំណែកឯកំណែទម្រង់ដីធ្លីដែលជាបញ្ហាដ៏ក្តៅគគុកនោះ រាជរដ្ឋាភិបាល បានអនុវត្តតែមិនទាន់ពេញលេញក្នុងការពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋដែលឯកជនកាន់កាប់ និងការចេញប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី** ពិសេសគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ និង"**មិនទាន់"បែងចែកដីធ្លីក្នុងក្របខណ្ឌដីសម្បទានដើម្បីគោលដៅសង្គមកិច្ចនៅឡើយ។** យោងតាមរបាយការណ៍អង្គការសិទ្ធិមនុស្ស និងផ្នែកច្បាប់មួយចំនួន រកឃើញថានៅតែមានការបន្តទន្ទ្រានដីទំនេររបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិពីសំណាក់អ្នកមានអំណាច និងប្រាក់។ ការសង្កេតរកឃើញថា រាជរដ្ឋាភិបាលបានខិតខំបង្កើត**អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី**នៅខែ កុម្ភៈ ឆ្នាំ ២០០៦។ ប៉ុន្តែរហូតមកដល់ពេលនេះស្ថាប័ននេះ បានដោះស្រាយករណីជម្លោះដីធ្លីតិចតួចបំផុត ក្នុងចំណោមបណ្តឹងចំនួនជាង២០០០ករណី ដែលបានប្តឹងដោយជនរងគ្រោះ។ ទោះបីមានដីរដ្ឋទំហំ ២០.០០០ ហិកតា ដែលត្រូវបានរំលោភយកដោយខុសច្បាប់ ត្រូវបានដកហូតមកវិញដោយអាជ្ញាធរនេះនៅឆ្នាំ ២០០៦ ក៏ដោយ ការសង្កេតឃើញក៏នៅមិនទាន់មានការរីកចំរើនក្នុងការបែងចែកដីសម្បទានសង្គមទៅដល់ប្រជាពលរដ្ឋនៅឡើយទេ។

បន្ទាប់ពីបានអនុម័តវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ដោយបន្ថយចំនួនសំលេងភាគច្រើនលើសលប់ពីរភាគបី មកជាសំលេងភាគច្រើនដាច់ខាត ៥០% + ១ សំលេង (សំរាប់ការបោះឆ្នោតជ្រើសរើស ការបោះឆ្នោតទុកចិត្ត ការអនុម័តយល់ព្រម ការទម្លាក់រចនាសម្ព័ន្ធរាជរដ្ឋាភិបាល សភា ជាដើមនោះ) ការសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជា បានក្លាយជាគណបក្សតែមួយគត់ដែលគ្របដណ្តប់ទៅស្ថាប័នរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា។ មានការដក ការចុះចេញពីតំណែង និងការផ្លាស់ប្តូរតំណែងរបស់មន្ត្រីរាជរដ្ឋាភិបាល និងសភាមកពីគណបក្សហ៊្វុនស៊ិនប៉ិចដៃគូរដ្ឋាភិបាលចំរុះ យ៉ាងហោចណាស់ **៩៥** រូប[៣]។ **អំណាចរបស់សភា ដើម្បីធ្វើឱ្យមានតុល្យភាពរាជរដ្ឋាភិបាលបានធ្លាក់ចុះ។** ការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ[៤] ក៏អាចនាំមកនូវការព្រួយបារម្ភថ្មីមួយថា អ្នកតំណាងរាស្ត្រនឹងបាត់បង់អភ័យឯកសិទ្ធិ និងមានការធ្លាក់ចុះសិទ្ធិបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ។

ការសង្កេតសភា និងតំណាងរាស្ត្ររកឃើញថា ចំនួនសកម្មភាពអ្នកតំណាងរាស្ត្រចុះបេសកកម្មទៅកាន់មណ្ឌលនានា និងការឡើងបញ្ចេញមតិនិងសកម្មភាពផ្សេងរបស់អ្នកតំណាងរាស្ត្រនៅក្នុងមន្ទីររដ្ឋសភាមានការកើនឡើងពីមួយខែទៅមួយខែប្រមាណ១០%

---

[៣] រួមមានមន្ត្រីនយោបាយ និងមន្ត្រីថ្នាក់មូលដ្ឋាន ដែលមាន ៧១ រូប (គិតពីថ្ងៃទី ១ មិនា ២០០៦ ដល់ ២៩ កក្កដា ២០០៦) បើយោងរបាយការណ៍រួមគ្នារបស់សមាគមអាដហុក លីកាដូ និងវេទិកាអាស៊ីចុះថ្ងៃទី ១៨ កញ្ញា ២០០៦ និងបន្ថែម ២៤ រូបទៀត (គិតពីថ្ងៃទី ៣០ កក្កដា ២០០៦ ដល់ ៣១ ធ្នូ ២០០៦) បើយោងតាមការរាប់របស់ខុមហ្វ្រែល។

[៤] មាត្រាទី ៥ ដែលចែងថាៈ *"តំណាងរាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ"*។ និងមាត្រាទី ៩ ដែលចែងថាៈ *"ការលើកលែងអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំរដ្ឋសភាត្រូវអនុវត្តនីតិវិធីដូចខាងក្រោមនេះៈ - រដ្ឋសភាអាចប្រជុំជាសម្ងាត់តាមការស្នើរសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ឬពីនាយករដ្ឋមន្ត្រី។ - កូរ៉ុមប្រជុំលើសពីពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ការអនុម័តតាមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។")*

។ តាមការសង្កេតរបស់ ខុមហ្វ្រែល បានរកឃើញថា នៅក្នុងឆ្នាំ ២០០៦ នេះ សមាជិករាជរដ្ឋាភិបាល**មិនបានអនុវត្តមាត្រា ៩៦** នៃរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលឆ្លើយតបនឹងសំនួររបស់អ្នកតំណាងរាស្ត្រឱ្យបានសកម្ម។ ក្នុងនោះ នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល មិនបានមកឆ្លើយឆ្លងជាមួយតំណាងរាស្ត្រ យ៉ាងសកម្មនៅក្នុងសម័យប្រជុំពេញអង្គនោះទេ បើទោះបីជាមានលិខិតអញ្ជើញយ៉ាងហោចណាស់ ១០ ច្បាប់ របស់អ្នកតំណាងរាស្ត្រស្នើឱ្យសមាជិករាជរដ្ឋាភិបាលចូលមកឆ្លើយសំនួរសមាជិកសភានោះក្តី។

ជាសរុប ការសំរេចបាននូវកម្មវិធីនយោបាយប្រមាណជាមធ្យម ១៥% ក្នុងមួយឆ្នាំ របស់រាជរដ្ឋាភិបាល និងសភា នឹងមិនអាចជំរុញឱ្យមានការបំពេញការអនុវត្តកម្មវិធីនយោបាយឱ្យបានពេញលេញ ទាំងបរិមាណ និងគុណភាព ទៅដល់ចុងអាណត្តិ របស់ខ្លួននាខែ កក្កដា ឆ្នាំ ២០០៨ នោះបានទេ ប្រសិនបើដំណើរការនៃការអនុវត្តនោះ នៅរក្សាល្បឿនយឺត និងខ្វះការចូលរួម។ ក្នុងករណីនេះក៏ដោយ បើសិនរាជរដ្ឋាភិបាល និងសភា បន្តខិតខំអនុវត្តកម្មវិធីនយោបាយ ដែលជាកំណែទម្រង់ស្នូល អភិបាលកិច្ចល្អ ប្រព័ន្ធតុលាការ និងច្បាប់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងសហវិមជ្ឈការ ពិសេសការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ។

*បេសកកម្មទី ២ ក្នុងចំណោមបេសកកម្មទាំងពីរ របស់ **ខុមហ្វ្រែល** គឺ "ជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះសាធារណជន យល់យ៉ាងច្បាស់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ មិនត្រឹមតែមុនពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង។ ដើម្បីសំរេចបេសកកម្មនេះ **ខុមហ្វ្រែល** រៀបចំការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។ លើកទឹកចិត្តការចូលរួមការតស៊ូមតិ បញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោត ដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត។ និងចុងក្រោយ ដោយផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលម្អៀង និងមិនប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោត។"*

**សូមអរគុណ!**

***សំរាប់ព័ត៌មានលំអិតសូមទាក់ទង:***


- **លោក គល់ បញ្ញា នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧**
- **លោក ម៉ារ សុផល ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១**
- **លោក គុយ ច័ន្ទដារិទ្ធ ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១**